រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

**បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®**

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

**Project WorldReach PWR ™**

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

056KH01A-01

# គ្រួសាររបស់ខ្ញុំ



## កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

## ៥៦

**បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®**

**T&M ™**

ទូលសូមអោយព្រះជាម្ចាស់ប្រើការសិក្សានេះ ដើម្បីពង្រឹងកិច្ចការ
បំរើសំរាប់ក្រុមគ្រួសារ ។

## គ្រួសាររបស់ខ្ញុំជាអំណោយទានរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់ជួយមនុស្សអោយអាចរៀបចំសណ្តាប់ធ្នាប់ក្នុងសង្គម
ដោយបង្កើតជារដ្ឋាភិបាល ច្បាប់ ទំនៀមទំលាប់ល្អ និង ខ្នាតគំរូ ។
គ្រួសារជាគ្រឹះសំខាន់ជាងគេរបស់សង្គម (កំណើតពិភពលោក
២:២៤) ។ ព្រះជាម្ចាស់ផ្ទាល់បានបង្កើតគ្រឹះរបស់សង្គមនេះ ។
បើសិនជាគ្រួសាររឹងមាំ នោះសង្គមទាំងមូលក៏រឹងមាំដែរ ។





**កំណត់ចំណាំ :**

© Project WorldReach © SEAN

**កំណត់ចំណាំ :**



# ប្រភពរបស់គ្រួសារ

ព្រះជាម្ចាស់បានបង្កើតឱ្យមានគ្រួសារទីមួយ នៅក្នុងសួនអេដែន ។ សូមអានអំពីផែនការរបស់ព្រះជាម្ចាស់ សំរាប់ក្រុមគ្រួសារ ដែលមានចែងនៅក្នុងបទព្រះគម្ពីរ កំណើតពិភពលោក ២:១៨-២៥, អេភេសូ ៥:២២-៣៣, អេភេសូ ៦:១-៤ ។

ព្រះជាម្ចាស់បង្គាប់អោយលោកអដាម និង នាងអេវ៉ាបង្កើតកូនចៅដែលជាព្រះពរ ។ បើយើងមិនថែរក្សាកូនរបស់ខ្លួន នោះជាអំពើបាប ។ ឪពុកម្តាយជាគ្រីស្តជន ត្រូវទទួលខុសត្រូវថែរក្សា និងអប់រំកូនរបស់ខ្លួនទាំងអស់ ។



© Project WorldReach © SEAN



តើមួយណាប្រសើរជាង ?

☐ មានកូនពីរ ឬ បីនាក់ដែលមានចំណីអាហារគ្រប់គ្រាន់ និង បានទទួលការអប់រំល្អ ។

☐ មានកូនប្រាំមួយនាក់ តែគ្មានលទ្ធភាពចិញ្ចឹមបីបាច់ថែរក្សា ត្រឹមត្រូវ ធ្វើអោយកូនៗស្ទើរស្លាប់ ដោយគ្មានចំណីអាហារ ទទួលទានគ្រប់គ្រាន់ ។



**កំណត់ចំណាំ :**

© Project WorldReach © SEAN

## ការយល់ចិត្តគ្នា និង សេចក្តីស្រឡាញ់ក្នុងគ្រួសារ

ប្តីប្រពន្ធដែលចេះគិតគូរពីគ្នាទៅវិញទៅមក តែងតែនិយាយប្រាប់គ្នា ដោយត្រង់ៗ និង ចែកចាយប្រាប់គ្នាពីគំនិតលាក់កំបាំងជ្រាលជ្រៅទាំងឡាយរបស់គេរៀងៗខ្លួន ។ ប្តីប្រពន្ធដែលធ្វើដូចនេះនឹងយល់ចិត្តគ្នា ហើយទទួលគំនិតគ្នាទៅវិញទៅមក ដែលនាំឱ្យពួកគេអាចរស់នៅដោយសុខសាន្ត និង ស្រុះស្រួលជាមួយគ្នា ។ បើប្តីប្រពន្ធមិនយល់ចិត្តគ្នាទេ នោះពួកគេនឹងមានទុក្ខលំបាកទាំងពីរនាក់ ។ បើសិនជាចាំបាច់ គ្រូគង្វាលរបស់ក្រុមជំនុំអាចជួយប្តីប្រពន្ធដូចនេះ ឱ្យចេះយល់ចិត្តគ្នា ចេះប្រាស្រ័យទាក់ទងជាមួយគ្នា ដើម្បីអាចរស់នៅដោយសុខសាន្ត និង ដោយសេចក្តីស្រឡាញ់ជាមួយគ្នា ។ ប្រពន្ធរបស់គ្រូគង្វាលត្រូវទៅសួរសុខទុក្ខប្តីប្រពន្ធជាមួយគ្រូគង្វាលជាប្តីរបស់ខ្លួន ដើម្បីជួយផ្តល់ដំបូន្មានដល់ប្តីប្រពន្ធទាំងនោះ គឺនិយាយជាមួយពួកគេត្រង់ៗអំពីការសង្ស័យ និង បញ្ហារបស់ពួកគេ ហើយជួយរកដំណោះស្រាយ ។



## កិច្ចការដែលត្រូវអនុវត្ត

- រៀបចំការសិក្សាពិស្តារអំពី អេភេសូ ៥:២១ ដល់ ៦:៤ ដើម្បីបង្រៀនក្រុមជំនុំរបស់អ្នក ដោយប្រើការទូន្មាន ដែលមាននៅក្នុងសៀវភៅនេះដែរ ។
- ជំរុញទឹកចិត្តឪពុកគ្រប់រូប ដែលនៅក្នុងក្រុមជំនុំ អោយធ្វើការថ្វាយបង្គំជាមួយគ្រួសារ និង បង្រៀនកូនៗរបស់ខ្លួន ។

**កំណត់ចំណាំ :**

តើយើងអាចជួយប្តីប្រពន្ធអោយចេះយល់ចិត្តគ្នា ដោយរបៀបណា ?

☐ ដោយស្តីបន្ទោសសមាជិកគ្រប់គ្នា ពេលអធិប្បាយនៅថ្ងៃអាទិត្យ ។

☐ ដោយផ្តល់ដំបូន្មានអោយពួកគេដោយអំណត់ នៅផ្ទះរបស់ពួកគេ ។

តើប្តីប្រពន្ធអាចយល់ចិត្តគ្នាបានដោយរបៀបណា ? ប្តីប្រពន្ធត្រូវពិភាក្សាពីការយល់ឃើញរបស់ពួកគេរៀងៗខ្លួន ជាពិសេស អំពីការគ្រប់គ្រងគ្រួសារ ការបែងចែកភារៈកិច្ចក្នុងគ្រួសារ និង ការចិញ្ចឹមបីបាច់ថែរក្សាកូន ។ ប្តីដែលជាគ្រីស្តជនត្រូវស្តាប់យោបល់របស់ប្រពន្ធគាត់ ។ រីឯប្រពន្ធត្រូវគោរពប្តីវិញ ។ គ្រួគង្វាលត្រូវជួយប្តីប្រពន្ធអោយរស់នៅជាមួយគ្នា ដោយរបៀបនេះ ។ ប្រពន្ធដែលខិតខំត្រួតត្រាលើប្តី ជាមនុស្សល្ងីល្ងើ ។ យោលទៅតាមបទព្រះគម្ពីរ អេភេសូ ៥:២១-២២ ប្រពន្ធដែលឈ្លាសវៃចុះចូលប្តីរបស់ខ្លួន ។ ប្តីដែលល្ងីល្ងើខិតខំប្រើកំឡាំង ដើម្បីត្រួតត្រាប្រពន្ធ ។ ឯប្តីឈ្លាសវៃ ថ្នាក់ថ្នមស្រឡាញ់ប្រពន្ធយ៉ាងមុតមាំ ដែលធ្វើអោយប្រពន្ធចុះចូលនឹងប្តី ដោយស្ម័គ្រចិត្ត និង ពេញចិត្ត ។



## ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ភារៈកិច្ចទីមួយរបស់ប្តីជាគ្រីស្តជន ចំពោះភរិយារបស់ខ្លួន គឺ :

_____

_____

២- ភារៈកិច្ចទីមួយរបស់ប្រពន្ធជាគ្រីស្តជន ចំពោះប្តីរបស់ខ្លួន គឺ :

_____

_____

៣- ភារៈកិច្ចទីមួយរបស់យុវជនជាគ្រីស្តជន គឺស្តាប់បង្គាប់ព្រះជាម្ចាស់ និង :

☐ ឪពុកម្តាយខ្លួន ។

☐ មិត្តភក្តិខ្លួន ។

៤- បើឪពុកបណ្តោយអោយកូនមានមិត្តភក្តិអាក្រក់ តើនឹងមានរឿងអ្វីកើតឡើង ? ។

_____

_____

© Project WorldReach © SEAN

## សណ្ដាប់ធ្នាប់របស់ព្រះជាម្ចាស់សំរាប់គ្រួសារ

ព្រះជាម្ចាស់បានរៀបចំគ្រួសារតាមសណ្ដាប់ធ្នាប់មួយ ។ បើគ្រួសារណាធ្វើតាមសណ្ដាប់ធ្នាប់នោះ គ្រួសារនោះនឹងចំរុងចំរើន ឯកភាពគ្នា មានការជឹកនាំល្អ និង ទទួលបានព្រះពរជាសុភមង្គល ។ បើគ្រួសារមិនធ្វើតាមសណ្ដាប់ធ្នាប់នោះទេ នោះគ្រួសារទាំងមូលនឹងមានទុក្ខលំបាក ។





បើមានការឈ្លោះប្រកែកគ្នា ឬ វាយតប់គ្នារវាងកូនៗ ឪពុកម្ដាយតែងតែស្ដីបន្ទោសកូនបង ។ តែមិនត្រូវគិតថា កូនបងជាអ្នកធ្វើឱ្យមានជំលោះកើតឡើង ព្រោះតែកូនបងធំជាងកូនប្អូននោះទេ ។ ជួនកាល កូនប្អូនអាចមានគំនិតធ្វើអោយបងខឹង ឈ្លោះ ដើម្បីឱ្យកូនបងជាប់ទោសប៉ុណ្ណោះ ! សូមកុំភ្លេចថា កូនប្អូនក៏ចេះធ្វើបាបដែរ ! ។

ត្រូវប្រុងប្រយ័ត្នអប់រំខ្លួនឯងដែរ ! បើសិនជាឪពុកម្ដាយចង់អោយកូនៗប្រកាន់តាមបទបញ្ញត្តិក្នុងគ្រួសារ ពួកគាត់ផ្ដាល់ត្រូវគោរពច្បាប់ទម្លាប់ដែរ ។ កូនៗឆាប់ដឹងពីអំពើពុតត្បុតរបស់ឪពុកម្ដាយណាស់ ។ ម្យ៉ាងទៀត ការមិនគោរពច្បាប់ទម្លាប់ ដូចជាទិញរបស់ដែលចោរលួចពីគេ ដោយតម្លៃថោកៗ កុហកបោកប្រាសគេនិយាយដើមគេ បើកម៉ូតូព្រហើន លួចបើកចាក់ពេលប្រឡងបង្ហិនលុយក្រុមគ្រួសារ ដោយសារល្បែងស៊ីសង និង ប្រព្រឹត្តអំពើអាក្រក់ផ្សេងៗទៀត ក្លាយជាគំរូអាក្រក់សំរាប់កូន ហើយបន្ថយអំណាចរបស់ឪពុកម្ដាយទៅលើកូន ។

ត្រូវអធិស្ឋាន និង អានព្រះគម្ពីរជាមួយកូនៗជាប់ជានិច្ច ។

**សណ្តាប់ធ្នាប់ក្នុងគ្រួសារតាមព្រះគម្ពីរ (អេភេសូ ៥:២១ និង ៦:៤) :**

**ព្រះគ្រីស្ត**

ព្រះគ្រីស្តជាព្រះសិរសារបស់ប្តី និង ជាព្រះសង្គ្រោះរបស់គ្រួសារទាំងមូល ។

**ប្តី**

ប្តីជាមេគ្រួសារនាំមុខប្រពន្ធ និង កូនៗគាត់ ហើយប្តីត្រូវស្រឡាញ់ ថែរក្សា និង ការពារអ្នកដែលព្រះជាម្ចាស់បានប្រទានអោយខ្លួន (អេភេសូ ៥:២៥-៣៣ និង ៦:៤) ។

**ប្រពន្ធ**

ប្រពន្ធត្រូវគោរពចុះចូលប្តី (អេភេសូ ៥:២១-២២) ។

**កូនៗ**

កូនៗត្រូវស្តាប់បង្គាប់ឪពុកម្តាយ (អេភេសូ ៦:១-៣) ។



មិនត្រូវស្រែកឡូឡាខ្លាំងដាក់កូនៗទេ ព្រោះនាំអោយកូនៗឃើញថាអ្នកជាឪពុកម្តាយមិនចេះទប់ចិត្ត ហើយនឹងលែងគោរពអ្នក ។ ត្រូវនិយាយជាមួយវា ពន្យល់វាពីអ្វីៗដែលវាត្រូវធ្វើ និង ប្រាប់ពីមូលហេតុ ។

ឪពុកម្តាយមិនត្រូវទិតៀនគ្នាទៅវិញទៅមក នៅចំពោះមុខកូនៗទេ ហើយប្តីប្រពន្ធក៏មិនត្រូវខិតខំធ្វើអោយកូនៗ កាន់ជើងខ្លួន ប្រឆាំងនឹងប្តី ឬ ប្រពន្ធខ្លួនដែរ ។

សេចក្តីសំខាន់បំផុត គឺធ្វើអោយកូនៗរស់នៅក្នុងក្រុមគ្រួសារមួយដែលរឹងមាំ មានសុវត្ថិភាព មានសេចក្តីស្រឡាញ់ មានការប្រាស្រ័យទាក់ទងគ្នា និង ចេះស្តាប់គ្នា ។ នៅក្នុងផ្ទះរបៀបនេះ នឹងមានការគោរពគ្នាទៅវិញទៅមក ជួយគិតគូរពីបញ្ហារបស់គ្នាទៅវិញទៅមក ទទួលស្គាល់គ្នាទៅវិញទៅមក បង្ហាញសេចក្តីស្រឡាញ់ចំពោះគ្នា (ដោយពាក្យសំដី ការប្រព្រឹត្ត និង ការអោបថ្នាក់ថ្នម ។ល។) ទាំងចំពោះកូនតូចៗ ទាំងចំពោះកូនដែលខ្ចចផងដែរ ។

បើសិនជាមានការឈ្លោះប្រកែក ឬ វាយតប់គ្នារវាងកូនៗ ឬ រវាងកូនៗ និង គ្រូរបស់វា ឬ សិស្សរួមថ្នាក់ ឬ មិត្តភក្តិ ។ល។ ឪពុកម្តាយវៃឆ្លាតត្រូវស្តាប់ទាំងសងខាង ដើម្បីឱ្យដឹងពីការពិត ។

© Project WorldReach © SEAN

ចំពោះក្មេងជំទង់ ការដាក់ទោសដោយរបៀបផ្សេង ក្រៅពីការដាក់ទោសលើរូបកាយ មានប្រសិទ្ធិភាពជាង ។ ឧទាហរណ៍ ដូចជាលែងអោយវាធ្វើអ្វីមួយ ដែលវាធ្លាប់មានសិទ្ធិធ្វើ ឬ ដាក់ការងារផ្ទះអោយធ្វើច្រើនជាងធម្មតា...។ល។ ។

ឪពុកម្តាយជាគ្រីស្តជន ដែលមានប្រាជ្ញា ចេះគោរពកូនៗរបស់ខ្លួន ហើយមិនមើលស្រាលចំពោះកូនៗទេ ។ បើសិនជាឪពុកម្តាយមានកំហុស នោះគាត់ត្រូវចេះសុំទោសកូនៗ ។ បើធ្វើដូចនេះ នឹងមានការគោរពគ្នាទៅវិញទៅមក ។ យើងមិនត្រូវដាក់ទោសកូនដោយសារកូនធ្វើខុស ដោយអចេតនាទេ (ដូចជាធ្វើឱ្យកំពប់សម្ពេលកូនលើកសម្ពចេញពីចង្ក្រានបាយ) ។ លើសពីនេះទៅទៀត យើងមិនត្រូវចង់អោយកូនល្អឥតខ្ចោះទេ ។ ការដាក់ទោសមិនត្រឹមត្រូវ ឬ ហួសហេតុបណ្តាលឱ្យកូនស្អប់ខ្លួនឯង និង មានឥទ្ធិពលអាក្រក់លើកូន ក្នុងរយៈពេលយូរ ។

មិនត្រូវប្រៀបធៀបកូនណាមួយជាមួយកូនមួយទៀត ឬ ស្រឡាញ់កូនណាមួយលើសកូនមួយទៀតជាដាច់ខាត ។



នៅក្នុងគ្រួសារគ្រីស្តជន តើអ្នកណាជាអ្នកនាំមុខប្រពន្ធ ? ។

_____

ប្តីដែលមានសេចក្តីស្រឡាញ់ មានតួនាទីគ្រប់គ្រងលើប្រពន្ធ ។ តើអ្នកណាជាសិរសារបស់ប្តី ? ។ _____

ព្រះគ្រីស្តជាព្រះសិរសារបស់ប្តី និង របស់ក្រុមជំនុំ ។

តើកូនត្រូវស្តាប់បង្គាប់អ្នកណា ? ។ _____

កូនៗរបស់គ្រួសារគ្រីស្តជន ស្តាប់បង្គាប់ឪពុកម្តាយរបស់ខ្លួន ក្នុងព្រះអម្ចាស់ ។ ដ្បិតកូនអាចស្គាល់ព្រះជាម្ចាស់បាន តាមរយៈគំរូ និង ការណែនាំរបស់ឪពុកម្តាយ ។ ព្រះជាម្ចាស់បង្កើតបទបញ្ញត្តិទាំងនេះ សំរាប់ឱ្យគ្រួសារមានសុខមាលភាព (បានសុខសាន្ត) ។

ឧទាហរណ៍នៃរបៀបគ្រប់គ្រងនេះ គឺកូនៗស្តាប់បង្គាប់ឪពុកម្តាយ ហើយប្រពន្ធចុះចូលនឹងប្តី ។ ប្តីទទួលខុសត្រូវលើកូនៗ និងប្រពន្ធ ស្របតាមព្រះហឫទ័យរបស់ព្រះគ្រីស្ត ហើយថែរក្សាគ្រួសារទាំងមូល ដោយសេចក្តីស្រឡាញ់ប្តូរផ្តាច់ដូចព្រះគ្រីស្ត ។ គ្រួសារទាំងមូលចុះចូលនឹងព្រះគ្រីស្ត ជាព្រះសិរសា ដែលជាអ្នកនាំមុខ ។

© Project WorldReach © SEAN

បើសិនជាយើងគោរពតាមរបៀបគ្រប់គ្រង ដែលព្រះជាម្ចាស់ប្រទានអោយនេះ គ្រួសារយើងនឹងចេះអប់រំគ្នា ចេះអត់ទោសឱ្យគ្នា និង ចេះស្រឡាញ់គ្នា ។ បើសិនជាឪពុកម្តាយពិតជាស្រឡាញ់កូនៗរបស់ខ្លួនមែន ឪពុកម្តាយនឹងកែតម្រូវកំហុសរបស់កូនៗ ដោយម៉ឺងម៉ាត់ ។

ទឹកចិត្តស្រឡាញ់គ្រួសារ នាំអោយសមាជិកគ្រួសារ មានចិត្តស្មោះត្រង់នឹងគ្នា និង ធ្វើអោយកាន់តែមានការទុកចិត្តគ្នាថែមទៀត ។ ទឹកចិត្តស្រឡាញ់គ្រួសារ នាំអោយអាចចៀសវាងការលេងសើចដែលមិនសមរម្យ និង នាំឱ្យអាចបំភ្លេចកំហុសពីមុន ។ ទឹកចិត្តស្រឡាញ់គ្រួសារ ធ្វើមិនអោយមានការតូចចិត្ត និង ជំលោះ តែធ្វើអោយចេះទប់កំហឹង ។





ត្រូវប្រកាន់តាមរបៀបរបបជានិច្ច ។ បើសិនជាកូនមិនស្តាប់បង្គាប់ ត្រូវតែវាយប្រដៅគ្រប់ពេលដែលវាមិនស្តាប់បង្គាប់ ទោះជាក្នុងស្ថានភាពណា ឬ ករណីណាក៏ដោយ ។ ឧទាហរណ៍ បើសិនជាកូនមិនស្តាប់បង្គាប់នៅមុខគេឯង ត្រូវយកវាចេញពីមុខគេភ្លាម ដើម្បីវាយប្រដៅ ។

ទាំងឪពុក ទាំងម្តាយ ត្រូវប្រើរបៀបប្រដៅដូចគ្នា ហើយគាំទ្រគ្នាទៅវិញទៅមក ។ ធ្វើដូចនេះ កូនៗមិនអាចធ្វើអោយឪពុកម្តាយទាស់ទែងគ្នាទេ ។

« មិនត្រូវធ្វើអោយកូនៗរបស់អ្នកមួម៉ៅ » ដោយសារតែបង្គាប់បញ្ជាអយុត្តិធម៌ ឬ មិនសមហេតុសមផល (អេភេសូ ៦:៤)ទេ ។ បើសិនជាអ្នកខឹងខ្លាំង សូមកុំដាក់ទោសលើរូបកាយកូន ព្រោះអ្នកអាចជ្រុលដៃជ្រុលជើង ! ។

ការអោយរង្វាន់បន្តិចបន្តួចដល់កូន និង និយាយលើកទឹកចិត្តកូននៅចំពោះមុខគ្រួសារទាំងមូលអំពីគុណសម្បត្តិរបស់វា ជាការល្អសំរាប់ពង្រឹងទំលាប់ល្អ និង ជួយកូនៗអោយប្រសើរឡើង ។

បើសិនជាកូនប្រព្រឹត្តខុសវិន័យតែមួយនៅក្នុងគ្រួសារ ឬ ព្រហើន កោងកាច ឪពុកម្តាយត្រូវវាយប្រដៅកូននោះភ្លាមៗ ដោយយុត្តិធម៌ និង ដោយគ្មានកំហឹង ។ ពេលដាក់ទោសកូន ត្រូវធ្វើយ៉ាងណា អោយកូនយល់ច្បាស់ថា ឪពុកម្តាយដាក់ទោសកូន ដោយសារកូនធ្វើខុស មិនមែនដោយសារឪពុកម្តាយលែងស្រឡាញ់កូននោះទេ ។ ពេលដែលដាក់ទោសកូនហើយ ត្រូវអោបកូន និង ជជែកប្រដៅណែនាំភ្លាមៗ ។

ការដាក់ទោសលើរូបកាយ មានប្រសិទ្ធិភាពជាងការស្រែកគំហក និង កំហឹង ។ ត្រូវដាក់ទោសដោយយុត្តិធម៌ អោយត្រូវនឹងកំហុស ហើយកុំវាយប្រដៅអោយហួសហេតុ ។ ឧទាហរណ៍ មិនត្រូវវាយក្បាលរបស់កូន ឬ ចាប់កូនៗគ្រវីជាដាច់ខាត ព្រោះការធ្វើដូចនេះអាចប៉ះពាល់អាក្រក់ដល់ខួរក្បាលរបស់កូន ។ កន្លែងដែលគួរវាយជាងគេ គឺកំប៉ែះគូទ ។ មិនត្រូវប្រៀនប្រដៅកូន ពេលអ្នកខឹងខ្លាំងទេ ។ កូនខ្លះនឹងកែប្រែការប្រព្រឹត្តរបស់ខ្លួន ដោយសារការស្តីបន្ទោស ដោយទន់ភ្លន់ ។ ក្នុងករណីនេះ មិនចាំបាច់វាយប្រដៅកូនៗទេ ។



សេចក្តីសង្ខេប :

- ប្រពន្ធដែលជាគ្រីស្តជន ត្រូវគោរពចុះចូលនឹងប្តីរបស់ខ្លួន (អេភេសូ ៥:៣៣) ។
- ប្តីដែលជាគ្រីស្តជនត្រូវស្រឡាញ់ប្រពន្ធរបស់ខ្លួន ដូចព្រះ-គ្រីស្តស្រឡាញ់ក្រុមជំនុំ/ព្រះសហគមន៍ដែរ គឺព្រះអង្គបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់ដើម្បីក្រុមជំនុំ/ព្រះសហគមន៍ (១ ពេត្រុស ៣:៧, អេភេសូ ៥:២៣-៣៣) ។
- កូនៗត្រូវស្តាប់បង្គាប់ឪពុកម្តាយខ្លួន (អេភេសូ ៦:១-៣) ។



## ការគោរពចំណងអាពាហ៍ពិពាហ៍

ព្រះជាម្ចាស់បង្គាប់ឱ្យបុរសចាកចេញពីឪពុកម្តាយទៅរួមរស់ជាមួយភរិយារបស់ខ្លួន (កំណើតពិភពលោក ២:២៤ និង ម៉ាថាយ ដែលនាំអោយគ្រួសារខ្មែររស់នៅបែបនេះ ។ ប៉ុន្តែ ប្តីប្រពន្ធរបស់ម្តាយទាំងសងខាង ។ ទោះជាឪពុកម្តាយអាចមានបំណងចង់ជួយកូនៗក៏ដោយ តែបើសិនជាឪពុកម្តាយខិតខំគ្រប់គ្រងលើគ្រួសារថ្មីរបស់កូនៗទៀត នោះនឹងធ្វើអោយមានឥទ្ធិពលអាក្រក់លើគ្រួសារថ្មីរបស់កូនៗ និង លើទំនាក់ទំនងរបស់កូនៗជាគូស្រករថ្មី ។ គូស្វាមីភរិយាត្រូវថែរក្សាឪពុកម្តាយចាស់ជរា ដែលត្រូវការជំនួយ ដោយសេចក្តីស្រឡាញ់ (១ ធីម៉ូថេ ៥:១៦) ។ ប៉ុន្តែ ស្វាមីភរិយាមិនត្រូវអោយឪពុកម្តាយជ្រៀតជ្រែក ឬ គ្រប់គ្រងក្នុងកិច្ចការរបស់គ្រួសារខ្លួនទេ ។

(យោងទៅតាមវប្បធម៌របស់ខ្មែរ ឪពុកម្តាយ បងប្អូន យាយតា តែងតែរស់នៅជាមួយគ្នា ។ មានហេតុផលល្អ និង ការចាំបាច់ដែលនាំអោយគ្រួសារខ្មែររស់នៅបែបនេះ ។ ប៉ុន្តែ ប្តីប្រពន្ធរបស់គ្រួសារនោះ មិនត្រូវពឹងផ្អែកលើឪពុកម្តាយទាំងស្រុង ហើយឪពុកម្តាយក៏មិនត្រូវខំគ្រួតត្រាលើជីវិតរបស់កូនខ្លួនហួសហេតុពេកនោះដែរ ។ ធ្វើស្រែចំការជាមួយគ្នា ផ្តល់ជំបូន្មានអោយគ្នាទៅវិញ



ឪពុកម្តាយដែលមានប្រាជ្ញា ត្រូវចេះប្រាប់កូនរបស់ខ្លួនអំពីអាកប្បកិរិយាដែលសមរម្យ និង អាកប្បកិរិយាដែលមិនសមរម្យ នៅក្នុងគ្រួសាររបស់ពួកគេ ។ ឪពុកម្តាយត្រូវសរសើរកូនខ្លួន ដោយទៀងទាត់ នៅពេលដែលកូនប្រព្រឹត្តត្រឹមត្រូវ ហើយត្រូវប្រៀនប្រដៅកូនអោយបានខ្ជាប់ខ្ជួន នៅពេលដែលកូនប្រព្រឹត្តមិនត្រឹមត្រូវ ។ ឪពុកម្តាយអាចមើលឃើញអាកប្បកិរិយាណាដែលល្អ និង អាកប្បកិរិយាណាដែលមិនល្អបាន ដោយពិនិត្យមើលសេចក្តីចែងក្នុងព្រះគម្ពីរ ហើយត្រូវដាក់ទោសកុមារអោយត្រឹមត្រូវសមហេតុផល និង សមល្មមសំរាប់កុមារ ។

ពន្យល់កូនៗថា ឪពុកម្តាយដាក់កិរិតទាំងនេះ សំរាប់ជាប្រយោជន៍ដល់កូនៗផ្ទាល់ និង ដោយសារឪពុកម្តាយស្រឡាញ់កូនៗខ្លាំងណាស់ ហើយថា បើជួនកាលការវាយប្រដៅអាចនាំអោយកូនឈឺចាប់ខ្លាំង នោះឪពុកម្តាយក៏ឈឺចាប់ជាមួយកូនដែរ ។

កូនៗដែលជាគ្រីស្តជនគោរព និង ស្តាប់បង្គាប់ឪពុកម្តាយរបស់ខ្លួន (សេរីភាព ២០:១២ និង អេភេសូ ៦:១-៣) ជាសេចក្តីអំណរ របស់ឪពុកម្តាយ ។ ឪពុកម្តាយត្រូវកែតម្រូវកូនៗ នៅពេលដែលពួកគេមិនស្តាប់បង្គាប់ ។

*« ក្មេងៗតែងតែជំពាក់ចិត្តនឹងភាពល្ងីល្ងើ ការវាយប្រដៅនឹងនាំវាអោយចេញឆ្ងាយពីភាពល្ងីល្ងើនោះ »* ។

(សុភាសិត ២២:១៥)

*« អ្នកណាមិនសូវប្រើរំពាត់ អ្នកនោះមិនស្រឡាញ់កូនទេ រីឯអ្នកដែលស្រឡាញ់កូន តែងតែវាយប្រដៅវា »* ។

(សុភាសិត ១៣:២៤)






ទៅមក ដោយសេចក្តីប្រាជ្ញា និង ចេះគោរពគ្នាទៅវិញទៅមក ជាការប្រសើរណាស់ ។ តែការរអ៊ូរទាំ ការច្រណែនគ្នា ការត្អូតត្រាលើគ្នា និង ការទាញយកតែផលប្រយោជន៍ពីគ្នា អាចបំផ្លាញគ្រួសារនោះ) ។

ប្តី និង ប្រពន្ធជា « រូបកាយតែមួយ »(អេភេសូ ៥:៣០-៣១) ។ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងការលែងលះគ្នាទេ ។ ព្រះ-អង្គហាមដាច់ខាតមិនអោយមានទំនាក់ទំនងស្នេហាក្បត់ប្តី ឬ ក្បត់ប្រពន្ធ (សេរីភាព ២០:១៤, ម៉ាថាយ ៥:៣១-៣២) ។

បើសិនជាប្តី ឬ ប្រពន្ធផិតក្បត់ តើអំពើផិតក្បត់នេះ មានឥទ្ធិពលអាក្រក់ទៅលើអ្នកណាខ្លះ ? ។ _____

_____

គ្រួសារទាំងមូលនឹងរងទុក្ខ ដោយសារការផិតក្បត់ ។ សូម្បីតែសង្គមក៏រងទុក្ខដែរ ។ ក្រុមជំនុំក៏ទទួលឥទ្ធិពលអាក្រក់ដែរ ហើយអ្នកដែលផិតក្បត់បំផ្លាញខ្លួនឯងទៀតផង ។ គ្រួសារនឹងបែកបាក់គ្នា ហើយលែងមានសេចក្តីសុខសាន្ត និង សុភមង្គល គឺកូនៗលែងមានសុវត្ថិភាព នៅក្នុងគ្រួសារ ។

គ្រីស្តជនគួរតែរៀបការតែជាមួយគ្រីស្តជនដូចគ្នា (២ កូរិនថូស ៦:១៤) ។ បើមិនប្រតិបត្តិតាមសេចក្តីបង្គាប់នេះ គឺនាំអោយមានគ្រោះថ្នាក់ធំខាងព្រលឹងវិញ្ញាណ ព្រោះប្តីប្រពន្ធមិនអាចជួយគ្នាទៅវិញទៅមកក្នុងជំនឿ ។ ហេតុនេះ គ្រីស្តជននឹងចុះខ្សោយ ។ ប្តីប្រពន្ធមានចិត្តគំនិតមិនចុះសម្រុងគ្នា គឺថាលក្ខណៈវិនិច្ឆ័យ គោលការណ៍ ចំណូលចិត្ត របៀបវាយតម្លៃ របៀបអប់រំ...។ល។ មិនដូចគ្នា ។ ប្រៀបដូចជាគេទឹមសត្វពីរ ដែលខុសគ្នាស្រឡះក្នុងនឹមតែមួយដូច្នោះដែរ ។



តើនឹងមានបញ្ហាអ្វីកើតឡើង បើសិនជាអ្នកជឿទៅរៀបការជាមួយអ្នកមិនជឿ ? ។ _____

_____

_____

_____



មនុស្សខ្ជិលនាំអោយខ្លួនក្រ មនុស្សឧស្សាហ៍នាំអោយខ្លួនមាន (សុភាសិត ១០:៤, ២៨:១៩) ។ យុវជនដែលឧស្សាហ៍ធ្វើការងារ មិនភ័យខ្លាចពេលខាងមុខទេ (សុភាសិត ១០:៥) ។

តើអ្នកអាចធ្វើដូចម្តេច ដើម្បីឱ្យឪពុកម្តាយនៅក្នុងក្រុមជំនុំរបស់អ្នកប្រៀនប្រដៅ និង អប់រំកូនៗរបស់ពួកគេត្រឹមត្រូវ ? ។

_____

_____

_____

## ជំបូន្មាន និង ខ្នាតគំរូសំរាប់ការប្រៀនប្រដៅកូន

ឪពុកម្តាយ ដែលស្រឡាញ់កូនៗរបស់ខ្លួន ប្រៀនប្រដៅកូនៗ និងអធិស្ឋានសំរាប់កូនៗ ។ សមាជិកជាច្រើនរបស់ក្រុមជំនុំថ្វាយកូនៗរបស់ពួកគេទៅព្រះជាម្ចាស់នៅចំពោះមុខអ្នកជឿឯទៀត ។ (លូកា ២:២២-២៣) ។ ព្រះយេស៊ូស្រឡាញ់ក្មេងតូចៗ (ម៉ាកុស ១០:១៣-១៦) ។ តើសមាជិករបស់អ្នកមានកូន ដែលពួកគេត្រូវថ្វាយទៅព្រះជាម្ចាស់ ស្របតាមទំនៀមទំលាប់របស់ក្រុមជំនុំអ្នកដែរឬទេ ? ។

© Project WorldReach © SEAN

**បង្រៀនកូនរបស់អ្នកដោយគំរូ និង ដោយពាក្យសំដីរបស់អ្នក អោយខិតខំធ្វើការងារដោយសុចរិតទៀងត្រង់ ។**

ស្តេចសាឡូម៉ូនប្រដៅថា÷ *«បើអ្នកគិតតែពីដេក អ្នកមុខជាធ្លាក់ខ្ជិនក្រ បើអ្នកចង់មានអាហារគ្រប់គ្រាន់ ចូរក្រោកឡើងពីព្រលឹម»* (សុភាសិត ២០:១៣) ។ ត្រូវធ្វើតាមគំរូសត្វស្រមោច ។ ស្រមោចខិតខំធ្វើការងារខ្លាំងណាស់ ។ ស្រមោចមិនដែលបង្ហាត ពេលធ្វើអំពើឆ្គតលីលា និង ខ្ជិលច្រអូសទេ (សុភាសិត ៦:៦-១១) ។

កូនប្រុសតែងតែចង់ធ្វើតាមគំរូរបស់ឪពុកខ្លួន ។





បុរសដែលទើបនឹងទទួលជឿ មិនត្រូវលែងលះប្រពន្ធរបស់ខ្លួនដោយសារតែប្រពន្ធមិនទាន់ទទួលជឿនោះទេ ។ គាត់ត្រូវខិតខំនាំប្រពន្ធមកថ្វាយព្រះគ្រីស្តអោយបានតាមរយៈគំរូល្អរបស់ខ្លួនគាត់ផ្ទាល់ (១ កូរិនថូស ៧:១២-១៦, ១ ពេត្រុស ៣:១-៧) ។

អ្នកជឿស្មោះត្រង់ មិនត្រូវខិតខំរកលេស ដើម្បីលែងលះប្រពន្ធរបស់ខ្លួនទេ ។ ហេតុអ្វី ? ។ _____

_____



ជួនកាល បុរស និង ស្ត្រីរស់នៅជាមួយគ្នា ដោយមិនបានរៀបការ ។ បើសិនជាពួកគេបានថ្វាយខ្លួនហើយ ពួកគេត្រូវបែកគ្នាឈប់រស់នៅរបៀបនេះ ឬ រៀបការជាមួយគ្នា (គឺថា សច្ចានៅចំពោះព្រះជាម្ចាស់ថា ពួកគេមានផែនការរស់នៅជាមួយគ្នាដោយស្មោះត្រង់ ជារៀងរហូត) ។

## ភារៈកិច្ចរបស់ប្តីជាគ្រីស្តជន

ប្តីជាគ្រីស្តជនស្រឡាញ់ប្រពន្ធរបស់ខ្លួន ហើយខិតខំធ្វើឱ្យគ្រួសារខ្លួនទាំងមូលមានសុភមង្គល និង សុខមាលភាព (សុខសាន្ត និង ចំរុងចំរើន) ។ គាត់ដឹកនាំក្រុមគ្រួសាររបស់គាត់អោយរស់នៅយ៉ាងសមរម្យស្របតាមព្រះជាម្ចាស់ (១ ភូរិនថូស ១១:៣ និង ១ ថេស្សាឡូនិក ២:១១-១២) ។



ប្តីត្រូវស្រឡាញ់ប្រពន្ធរបស់ខ្លួន ដូចព្រះគ្រីស្តស្រឡាញ់ក្រុមជំនុំ / ព្រះសហគមន៍ដែរ (អេភេសូ ៥:២៥) ។ ប្តីត្រូវស្រឡាញ់ប្រពន្ធរបស់ខ្លួនអោយដូចស្រឡាញ់ខ្លួនឯងដែរ ។ ប្តីផ្គត់ផ្គង់ខ្លួនឯង ថែរក្សាខ្លួនឯងយ៉ាងណា ត្រូវផ្គត់ផ្គង់ និង ថែរក្សាប្រពន្ធខ្លួនយ៉ាងនោះដែរ (អេភេសូ ៥:២៨-៣០, ១ ពេត្រុស ៣:៧, កូឡូស ៣:២០) ។



## ត្រូវការពារកូនរបស់អ្នកពីសុរា និង អំពើអាក្រក់ផ្សេងៗទៀត ។

ស្តេចសាឡូម៉ូនមានព្រះបន្ទូលថា យុវជនមានប្រាជ្ញាមិនប្រមឹកស្រាទេ ។ យុវជនមានប្រាជ្ញាមិនសេពគប់ នឹងមនុស្សប្រមឹកទេ (សុភាសិត ២៣:២០) ។ មនុស្សប្រមឹករមែងធ្លាក់ខ្លួនក្រ ព្រោះគេរកតែស្រា មិនរកការងារធ្វើទេ (សុភាសិត ២៣:២១) ។

នៅក្នុង សុភាសិត ២៣:២៩-៣២ ស្តេចសាឡូម៉ូនសួរថា÷

*«តើអ្នកដែលត្រូវគេមើលងាយ អ្នកដែលគេនឹកហួសចិត្ត ជានរណា ? »*

*«តើអ្នកដែលរករឿងឈ្លោះ អ្នករអ៊ូរទាំ ជានរណា ? »*

*«តើអ្នកដែលត្រូវគេវាយ ដោយឥតហេតុផល អ្នកដែលក្រហមភ្នែក ជានរណា ? »*

*«គឺអ្នកវក់នឹងស្រា អ្នកដែលចូលចិត្តស្រាខ្លាំង ។ កុំចាប់ចិត្តនឹងស្រាដែលមានពណ៌ស្រស់ល្អធ្វើអោយកែវភ្លឺថ្លា ហើយហូរចូលក្នុងបំពង់កយ៉ាងស្រួលនោះឡើយ ។ នៅទីបំផុត ស្រានោះធ្វើអោយអ្នកឈឺចាប់ ដូចពស់អាសិរពិសចឹក » ។*

© Project WorldReach © SEAN

មនុស្សល្ងីល្ងើ តែងតែមើលងាយការប្រៀនប្រដៅរបស់ឪពុក រីឯអ្នកដែលស្តាប់តាមការប្រៀនប្រដៅ ជាមនុស្សឆ្លាត (សុភាសិត ១៥:៥) ។

កូនមានប្រាជ្ញា រមែងធ្វើអោយឪពុកសប្បាយចិត្ត រីឯកូនខិលខូចធ្វើអោយម្តាយព្រួយបារម្ភ (សុភាសិត ១០:១) ។

**ត្រូវជួយកូនរបស់អ្នក អោយអាចចៀសវាងមិនសេពគប់នឹងមនុស្សអាក្រក់ ។**

ស្តេចសាឡូម៉ូនទូន្មានយុវជន កុំឱ្យទាក់ទងនឹងមនុស្សកាចសាហាវ និង ស្ត្រីអាក្រក់ ។ យុវជនត្រូវចៀសអោយឆ្ងាយពីមនុស្សអាក្រក់ទាំងនេះ (សុភាសិត ៥:៣-៥) ។






ប្តីជាគ្រីស្តជនត្រូវខិតខំធ្វើការងារខ្លាំងណាស់ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ខ្លួន ។ គាត់ត្រូវថែរក្សា និង ប្រៀនប្រដៅកូនៗរបស់គាត់ (អេភេសូ ៦:៤) ។ អ្នកណាដែលមិនផ្គត់ផ្គង់គ្រួសាររបស់ខ្លួននោះ អាក្រក់ជាងអ្នកមិនជឿទៅទៀត ពីព្រោះអ្នកមិនជឿក៏ចេះថែរក្សាគ្រួសាររបស់ពួកគេដែរ (១ ធីម៉ូថេ ៥:៨) ។

តើអ្នកបានចំណាយពេលគ្រប់គ្រាន់ ដើម្បីនៅជាមួយប្រពន្ធ និងកូនៗអ្នក ដើម្បីស្រឡាញ់ថ្នាក់ថ្នមពួកគេអោយបានច្រើន បង្រៀនព្រះគម្ពីរដល់ពួកគេ និង ជួយគេខាងសេចក្តីត្រូវការ ខាងគំនិតប្រាជ្ញា ខាងសំភារៈ ខាងព្រលឹងវិញ្ញាណ និង ខាងផ្លូវចិត្តដែរឬទេ ? ។ បើសិនជាមិនបានធ្វើដូចខាងលើនេះទេ សូមរៀបចំកាលវិភាគរបស់អ្នកឡើងវិញភ្លាម ដើម្បីទុកពេលវេលាធ្វើកិច្ចការខាងលើនេះជាមួយគ្រួសារ ។ តើអ្នកត្រូវកែប្រែអ្វីខ្លះ នៅក្នុងកាលវិភាគរបស់អ្នក ? ។



## ភារៈកិច្ចរបស់ប្រពន្ធជាគ្រីស្តជន

ប្រពន្ធជាគ្រីស្តជន ចុះចូលប្តីខ្លួន ដោយសេចក្តីស្រឡាញ់ ។ នាង ត្រូវជួយប្តីដឹកនាំគ្រួសារ (កូឡុស ៣:១៨) ។ ប្តីប្រពន្ធធ្វើការ រួមជាមួយគ្នា ជាដៃគូ ក្រោមការដឹកនាំរបស់ប្តី ។

ប្រពន្ធជាគ្រីស្តជនគាំទ្រប្តីគាត់ ក្នុងកិច្ចការបំរើព្រះជាម្ចាស់របស់ ប្តីគាត់ ហើយយ៉ាងតិចណាស់ ក៏គាត់ធ្វើកិច្ចការបំរើក្រុមគ្រួសារ គាត់ និង អ្នកជិតខាងដែរ ។ គាត់ឧស្សាហ៍ធ្វើការងារណាស់ ហើយប្តី និង កូនៗរបស់គាត់ ត្រូវកោតសរសើរគាត់ (សុភាសិត ៣១:១០-៣១) ។

នៅពេលដែលឪពុកមិននៅផ្ទះ ម្តាយវាយប្រដៅកូនៗ ស្របទៅតាមច្បាប់ទំលាប់ក្នុងគ្រួសារ ដែលប្តីប្រពន្ធបានព្រមព្រៀងគ្នា ។ ប្តីប្រពន្ធត្រូវព្រមព្រៀងគ្នាចំពោះច្បាប់ទំលាប់ទាំងនេះ ហើយ ប្រកាន់ទុកជាប់ជារហូត គ្មានកែប្រែ ដើម្បីអោយកូនទុកចិត្ត ។

មិនត្រូវគំរាមកូនដោយពាក្យដូចនេះថា «ចាំឪពុកឯងមកវិញសិន ទុកអោយគាត់ដាក់ទោសឯងចុះ» ទេ ។ បើធ្វើដូចនេះ នាំឱ្យ កូនភ័យខ្លាចឪពុកពេក ដែលនាំឱ្យអំណាចគ្រប់គ្រងរបស់ម្តាយ ចុះខ្សោយ ។



ត្រូវបង្រៀនកូនឱ្យចេះពឹងផ្អែកលើព្រះជាម្ចាស់ទាំងស្រុង មិនមែនពឹងលើការចេះដឹងរបស់ខ្លួននោះទេ ។ នោះព្រះជាម្ចាស់នឹងត្រួសត្រាយផ្លូវប្រសើរបំផុតសំរាប់កូន (សុភាសិត ៣:៥-៧) ។

ត្រូវជួយកូនអ្នក អោយទទួលការប្រៀនប្រដៅរបស់ព្រះអម្ចាស់ ។ ឪពុកល្អកែតម្រង់កូន ដោយសុចរិត និង ដោយសេចក្តីស្រឡាញ់ ដូចជាព្រះអម្ចាស់កែតម្រូវបុត្រធីតារបស់ព្រះអង្គដែរ (សុភាសិត ៣:១១-១២) ។

**ត្រូវជួយកូនរបស់អ្នកអោយចេះស្តាប់បង្គាប់ឪពុកម្តាយ ។**

ស្តេចសាឡូម៉ូនប្រដៅកូនៗ ឱ្យស្តាប់តាមឪពុកម្តាយរបស់ខ្លួន ។ អ្វីៗដែលឪពុកម្តាយបង្រៀននោះ ត្រូវគោរពតាម ពីព្រោះឪពុកម្តាយមានបទពិសោធន៍ច្រើនជាងកូន (សុភាសិត ១:៨-៩, សុភាសិត ៤:១-៥) ។

បើសិនជាយុវជននឹកចាំពីពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយខ្លួន យុវជននោះនឹងដើរតាមផ្លូវត្រូវជានិច្ច (សុភាសិត ៣:១-២) ។



© Project WorldReach © SEAN

## ដំបូន្មានសំរាប់ឪពុកម្តាយ

**ត្រូវជួយកូនរបស់អ្នកអោយចេះស្តាប់បង្គាប់ព្រះជាម្ចាស់ ។**

ត្រូវជួយយុវជនអោយស្គាល់ព្រះជាម្ចាស់ ។ ការគោរពកោតខ្លាច ព្រះអម្ចាស់ ជាប្រភពនៃការចេះដឹង ។ បើសិនជាកូនមិនស្គាល់ ព្រះជាម្ចាស់ កូននោះនឹងល្ងង់ខ្លៅ (សុភាសិត ១:៧) ។

ជួយយុវជនអោយចេះអានព្រះបន្ទូលព្រះជាម្ចាស់ ហើយរក្សាក្រិត្យ វិន័យរបស់ព្រះជាម្ចាស់ទុកក្នុងចិត្ត ប្រយោជន៍អោយព្រះអង្គការ ពារពួកគេ (សុភាសិត ២:១-៥, ១០-១២) ។ ការដែលឪពុក ម្តាយនាំគ្រួសារថ្វាយបង្គំរាល់ថ្ងៃ សំខាន់ណាស់ ។ «ត្រូវបង្ហាត់ បង្រៀនកូនអោយទៅតាមផ្លូវត្រូវ ដូចនេះ នៅពេលដែលកូនចាស់ ទៅ កូនក៏មិនងាកចេញពីផ្លូវនេះដែរ» *(សុភាសិត ២២:៦)* ។





## ភារៈកិច្ចរបស់ឪពុកម្តាយជាគ្រីស្តជន

ឪពុកម្តាយជាគ្រីស្តជននាំកូនឱ្យមានជំនឿ ។ ពួកគាត់ស្រឡាញ់ ថែរក្សា បង្រៀន និង ប្រដៅកូនៗ (អេភេសូ ៦:៤) ។ ពួកគាត់ ប្រៀនប្រដៅកូន ដោយយុត្តិធម៌ ហើយមានចិត្តស្រឡាញ់ និង មានទំនាក់ទំនងជាមួយកូន គ្មានប្រែប្រួល ។ ពួកគាត់គ្មានពុត ត្បុត ឬ ថាផ្សេង ធ្វើផ្សេងទេ តែប្រព្រឹត្តខ្លួនតាមអ្វីៗដែលគាត់ បង្រៀនប្រាប់កូនៗ ។ ព្រះយេស៊ូលើកពរក្មេង ហើយប្រទានពរ អោយក្មេងៗ ។ ព្រះអង្គកែតម្រូវសិស្សរបស់ព្រះអង្គនៅពេល ដែលពួកសិស្សចង់ដេញក្មេងៗអោយទៅឆ្ងាយពីព្រះអង្គ (ម៉ាកុស ១០:១៣-១៦) ។ កូនៗជាព្រះពរដែលព្រះជាម្ចាស់ប្រទានអោយ (ទំនុកតម្កើង ១២៧:៣-៥) ។



© Project WorldReach © SEAN

## ភារៈកិច្ចរបស់ក្រុមជំនុំចំពោះក្រុមគ្រួសារ

ក្រុមជំនុំបានរឹងមាំ ពេលមានក្រុមគ្រួសារទាំងមូលៗជាច្រើន ចូលរួមជាសមាជិក ។ ក្រុមជំនុំដែលមានតែសមាជិកម្នាក់របស់គ្រួសារ ឬ មានច្រើនតែកុមារ ឬ យុវជនជាសមាជិក នឹងនៅតែខ្សោយរហូត ។ ក្រុមជំនុំត្រូវពង្រឹងគ្រួសារ ហើយរក្សាគ្រួសារអោយនៅរួបរួមគ្នា ។ ព្រះជាម្ចាស់ស្វែងរកគ្រួសារទាំងមូលៗ ។ នៅពេលដែលនាងលីឌីថ្វាយខ្លួន ហើយនាងក៏នាំក្រុមគ្រួសារនាងទាំងអស់មកថ្វាយព្រះគ្រីស្តដែរ (កិច្ចការ ១៦:១៤-១៥) ។ ដូចគ្នានេះដែរ លោកគ័រនេល្យូសជានាយទាហាន បានថ្វាយខ្លួនព្រមជាមួយនឹងក្រុមគ្រួសាររបស់គាត់ទាំងអស់ (កិច្ចការ ១០:២៤, ៤៤-៤៨) ។ ឆ្នាំគុកនៅក្រុង ភីលីព (កិច្ចការ ១៦:៣៣-៣៤) និង លោកគ្រីស្ពូសនៅក្រុងកូរិនថូស (កិច្ចការ ១៨:៨) ក៏ទទួលដំណឹងល្អព្រមជាមួយនឹងក្រុមគ្រួសាររៀងៗខ្លួនដែរ ។

តើក្រុមជំនុំរបស់អ្នកធ្វើកិច្ចការអ្វីខ្លះ ដើម្បីនាំគ្រួសារទាំងមូល ឱ្យថ្វាយខ្លួន ? ។ _____

_____

_____

_____



តើអ្នកអាចជំរុញឪពុកម្តាយអោយបង្រៀនកូនៗ អោយមានជំនឿដោយរបៀបណា ? ។ _____

_____

_____

_____

បុរសខ្លះទុកអោយប្រពន្ធខ្លួន ធ្វើការប្រៀនប្រដៅកូនៗ ។ ធ្វើដូចនេះ មិនសមរម្យទេ ។ គ្រួគង្វាលឈ្លាសវៃត្រូវបង្រៀនឱពុកៗឱ្យចេះប្រៀនប្រដៅកូនៗ និង ផ្តល់ដំបូន្មានដល់កូនៗគាត់ ។ ឱពុកមិនត្រូវចាំអោយកូនធ្វើខុសសិន ទើបប្រៀនប្រដៅទេ តែគាត់ត្រូវចាប់ផ្តើមផ្តល់ដំបូន្មានតាំងពីកូននៅតូច ។

ស្តេចសាឡូម៉ូនរស់នៅ មុនព្រះគ្រីស្តប្រសូត្រមកជាមនុស្ស រាប់ពាន់ឆ្នាំហើយ ។ ទ្រង់បានសរសេរសៀវភៅព្រះគម្ពីរ « សុភាសិត » ដែលមានប្រយោជន៍សំរាប់បង្រៀនដល់យុវជន ។

សៀវភៅព្រះគម្ពីរសុភាសិត មានពាក្យសុភាសិតខ្លីៗស្រួលចាំជាច្រើន ដែលឪពុកអាចយកមកណែនាំកូនរបស់ខ្លួនបាន ។ នៅទំព័របន្ទាប់នេះ ជាឧទាហរណ៍ខ្លះៗ :

© Project WorldReach © SEAN